ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ២ លេខ : ១១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៩



# មាតិកាអត្ថបទ

**កិច្ចប្រជុំទី១ រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល**

**ល.រ ឈ្មោះអត្ថបទ**


១. សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា ........ ១–២

២. សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងសេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធាននៃការ–បង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ........ ៣–៤

៣. ប្រជុំឡើងវិញលើសេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យាទំនើប ........ ៥
ប្រជុំឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ........ ៦

៤. បទបង្ហាញស្តីពីការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិនៅកម្ពុជា ........ ៧

៥. សកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ........ ៨–១៣

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតគណៈស្ថាបត្យករកម្ពុជា



កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០ នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **សំ សុខផល** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និងឯកឧត្តម **ប៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈស្ថាបត្យករកម្ពុជា ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ក្នុងការធ្វើសមាហរណកម្មវិជ្ជាជីវៈស្ថាបត្យកម្មកម្ពុជាចូលក្នុងតំបន់ ជាពិសេសក្នុងសហគមន៍អាស៊ាន និងដើម្បីចូលរួមអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមករបស់អាស៊ាន លើសេវាកម្មស្ថាបត្យកម្មដែលកម្ពុជាយើងបានចុះហត្ថលេខាក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១២កន្លងមក។

ការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជានេះ មានគោលបំណងជាសារវន្តដូចខាងក្រោម៖

-រួមចំណែករៀបចំវិជ្ជាជីវៈស្ថាបត្យកម្មឲ្យកាន់តែល្អប្រសើរដើម្បីការពារកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ស្ថាបត្យករ

-រួមចំណែកថែរក្សាការពារ អភិវឌ្ឍស្ថាបត្យកម្មខ្មែរ នឹងលើកកម្ពស់អត្តសញ្ញាណជាតិ

-ពង្រឹង និងលើកកម្ពស់សមត្ថភាពនិងគុណភាពបន្ថែមដល់ស្ថាបត្យករដែលប្រកបមុខរបបអាជីវកម្ម ដោយគោរពខ្ជាប់ខ្ជួននូវក្រមសីលធម៌

-ធានាឲ្យបានការប្រកបវិជ្ជាជីវៈស្ថាបត្យកម្មមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ស្ថិរភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងការការពារទេសភាពធម្មជាតិនិងបេតិកភណ្ឌជាតិ

-ពង្រឹងនិងបើកទូលាយទំនាក់ទំនងកិច្ចសហប្រតិបត្តិការ



ជាតិ និងអន្តរជាតិ ព្រមទាំងធ្វើសមាហរណកម្មស្ថាបត្យកម្មជាតិចូលក្នុងពិភពលោក និងក្នុងតំបន់ជាពិសេសជាមួយបណ្តាប្រទេសអាស៊ាន



-ទទួលស្គាល់ទេព្យកោសល្យរបស់ស្ថាបត្យករកម្ពុជា ដើម្បីឲ្យមានគោរម្យងារជាស្ថាបត្យករជាតិ និងអន្តរជាតិ

-រួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈស្ថាបត្យកម្ម ដើម្បីអភិវឌ្ឍធនធានមនុស្សឲ្យស្របតាមតម្រូវការសង្គមជាតិ តម្រូវការតំបន់និងពិភពលោក

-លើកទឹកចិត្តដល់ស្ថាបត្យករដែលបង្កើតទស្សនៈស្ថាបត្យកម្មថ្មីៗ និងស្ថាបត្យកម្មដែលមានលក្ខណៈអត្តសញ្ញាណ ជាតិគួបផ្សំនឹងសម័យទំនើប(១)។

អង្គប្រជុំបានពិភាក្សាយ៉ាងផុលផុសលើសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ហើយបានធ្វើការកត់សម្គាល់ថា ព្រះរាជក្រឹត្យនេះមានខ្លឹមសារផ្ទុយនឹងច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤ ត្រង់មាត្រា១៥ ដែលចែងថា "ឯកសារនិងប្លង់ចាំបាច់សម្រាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់សំណង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករ ខ្មែរមានសញ្ញាបត្រ ឬជនណាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច "។

លក្ខខណ្ឌដែលទាមទារអំពីសញ្ញាបត្រនិងទាមទារការ ទទួលស្គាល់ខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជាលទ្ធផល អង្គប្រជុំទី១បានស្នើឲ្យក្រសួងសាមីយក សេចក្តីព្រាងព្រះរាជក្រឹត្យនេះទៅរៀបចំឡើងវិញ ហើយនឹងដាក់ប្រជុំម្តងទៀតនៅពេលក្រោយ៕

(១)អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុលើសេចក្តី ព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា។

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី
# ការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ
## និងសេចក្តីព្រាងអនុក្រឹត្យស្តីពី
# វិធាននៃការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ

កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០ នាទី និង ម៉ោង ១៥:០០នាទី និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **សំ សុខផល** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និង ឯកឧត្តម **ប៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សា លើ (១) **សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ** (២) **សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាននៃការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ** ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។





ដោយផ្អែកតាមស្មារតីនៃអង្គប្រជុំទី១ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) និងសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាននៃការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ក្នុងគោលបំណងចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល តាមរយៈការអភិវឌ្ឍមួយប្រកបដោយនិរន្តភាព តាមរយៈការប្រើប្រាស់ឲ្យអស់ធនធាន និងសក្តានុពលដែលមាន និងធានាឲ្យមាននូវការចូលរួមពេញលេញ ឯកភាព សាមគ្គី តម្លាភាព អភិបាលកិច្ចល្អ ប្រសិទ្ធភាព និងគណនេយ្យភាព ឈានទៅរកភាពជាម្ចាស់និងការអភិវឌ្ឍបានដោយខ្លួនឯង។ ទាំងនេះគឺស្រប

ទៅនឹងគោលនយោបាយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលមានកំណើនការងារ សមធម៌ និងប្រសិទ្ធភាពដែលមាន អភិបាលកិច្ចល្អជាស្នូល។



គ.អ.ភ គឺជាយន្តការមូលដ្ឋានគន្លឹះមួយដែលជួយធ្វើឲ្យយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្រោមមគ្គុទេសក៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាន់តែទទួលបានជោគជ័យខ្លាំងក្លាថែមទៀត តាមរយៈការស្តាបនា និងកៀរគរបាននូវការជឿទុកចិត្ត និងចូលរួមពីមូលដ្ឋាន ពីសហគមន៍ជាតិ និងពីសហគមន៍អន្តរជាតិ ជាពិសេសគឺចូលរួមអនុវត្តឲ្យបានជោគជ័យនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាលបានបង្កើត គ.អ.ភ. តាំងពីឆ្នាំ១៩៩៩ តាមស្មារតីនៃសេចក្តីសម្រេចលេខ០២ ស.ស.រ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩។ ក្រសួងអភិវឌ្ឍន៍ជនបទបានចេញសារាចរណែនាំ លេខ០១ សរណន.អជប ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដើម្បីអនុវត្តសេចក្តីសម្រេចខាងលើ។ រហូតមកដល់បច្ចុប្បន្ននេះគណៈកម្មាធិការអភិវឌ្ឍន៍ភូមិត្រូវបានបង្កើតឡើងចំនួន ៨.៦៩៧ ភូមិ នៃចំនួនភូមិសរុបស្មើនឹង ៦៣ ភាគរយ គ្របដណ្តប់ទាំង ២៤ រាជធានី–ខេត្ត ដោយមានការជួយគាំទ្រពីរាជរដ្ឋាភិបាល និងការគាំទ្រពីដៃគូអភិវឌ្ឍន៍។ ក៏ប៉ុន្តែក្រោយពីការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់ តួនាទី និងភារកិច្ច គ.អ.ភ មិនទាន់ត្រូវបានកែសម្រួលឡើងវិញឲ្យស្របតាមដំណើរការអភិវឌ្ឍន៍មូលដ្ឋាន ពិសេសគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ជាពិសេសរចនាសម្ព័ន្ធអភិវឌ្ឍន៍និងទំនាក់ទំនងរវាង គ.អ.ភ. និងក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលបានធ្វើឲ្យស្ថានភាពបច្ចុប្បន្នរបស់ គ.អ.ភ មានភាពមិនច្បាស់លាស់។

កត្តាទាំងនេះធ្វើឲ្យមានកង្វះការគាំទ្រដែលតែងតែមានពីមុនមក ជាពិសេសពីដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធ ធ្វើឲ្យបច្ចុប្បន្នភាពរបស់ គ.អ.ភ. ដែលមានស្រាប់ ៨១ ភាគរយ ផុតអាណត្តិ និងត្រូវបោះឆ្នោតឡើងវិញ[១]។

អង្គប្រជុំបានឯកភាពពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារទាំងពីរនេះ ហើយបានធ្វើការកែសម្រួលទម្រង់ និងខ្លឹមសារមួយចំនួន ដើម្បីឲ្យសេចក្តព្រាងទាំងពីរនេះកាន់តែល្អប្រសើរ។

អង្គប្រជុំទី១បានបញ្ចប់ការពិភាក្សាលើសេចក្តីទាំងពីរនេះ។

[១]អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ។

## ប្រជុំឡើងវិញលើសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពី

# ជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យាទំនើប



កាលពីថ្ងៃទី០៨ , ២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី និងវេលាម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ឈាយលី** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) និង **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ **សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យាទំនើប** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងបរិស្ថាន សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

គួររំលឹកថាសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើបបានដាក់ឆ្លងកិច្ចប្រជុំទី១ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ហើយជាលទ្ធផលនាពេលនោះ អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារចង្អៀតរវាង ក.វ.ស. ក្រុមប្រឹក្សាអ្នកច្បាប់ និងក្រសួងបរិស្ថាន ដើម្បីរៀបចំសេចក្តីព្រាងផែនការនេះឡើងវិញ។

អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងផុលផុសលើសេចក្តីព្រាងផែនការកែសម្រួលថ្មីនេះ ហើយបានសម្រេចកែសម្រួលរយៈពេលនៃការអនុវត្តផែនការនេះពីឆ្នាំ២០១០-២០១៤ ដើម្បីឲ្យទាន់សភាពការណ៍ និងកែលំអខ្លឹមសារដើម្បីធ្វើឲ្យអត្ថន័យ និងអត្ថរូបកាន់តែល្អប្រសើរ។

អង្គប្រជុំទី១បានបញ្ចប់ការពិភាក្សាជាបណ្តោះអាសន្ននៅទំព័រទី១១៕



## ប្រជុំឡើងវិញលើសេចក្តីព្រាងអនុក្រឹត្យស្តីពី

# នីតិវិធីនៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ិច ឈុន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង លោកជំទាវ **លី វួចឡេង** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ សេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីនៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងធនធានទឹក និងឧតុនិយម សមាជិក អគ្គលេខាធិការរង ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។





គួររំលឹកថាសេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍កសិករប្រើប្រាស់ទឹក បានដាក់ឆ្លងកិច្ចប្រជុំទី១ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ហើយជាលទ្ធផលនាពេលនោះ អង្គប្រជុំបានសម្រេចបង្កើតក្រុមការងារចង្អៀតរវាង ក.វ.ស. ក្រុមប្រឹក្សាអ្នកច្បាប់ និងក្រសួងបរិស្ថាន ដើម្បីជួយរៀបចំសេចក្តីព្រាងនេះឡើងវិញ។

អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់លើសេចក្តីព្រាងអនុក្រឹត្យកែសម្រួលថ្មីនេះ ហើយបានសម្រេចដូចខាងក្រោមនេះ៖

–ដាក់ចំណងជើងឲ្យដូចមាត្រា១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ដែលជាបង្អែកក្នុងការបង្កើតអនុក្រឹត្យនេះ

– ក្រសួងត្រូវរៀបចំជំពូកទី២និងជំពូកទី៣ ឡើងវិញ។ អង្គប្រជុំបានបញ្ចប់ការពិភាក្សាបណ្តោះអាសន្ននៅជំពូកទី១៕

## បទបង្ហាញស្តីពី

# ការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិនៅកម្ពុជា

កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង ១៤:០០ នាទី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) បានរៀបចំបទបង្ហាញ ស្តីពីការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិនៅកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **គឹម សយសាម៉ាឡែន** អនុប្រធាន ក.ស.វ. និងដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា ក.ស.វ. ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គលេខាធិការដ្ឋាន ក.ស.វ.។

ក្នុងឱកាសនោះ មានជំនាញការមកពីធនាគារអភិវឌ្ឍន៍ជនបទចំនួនពីររូបបានធ្វើបទឧទេសនាមលើប្រធានបទចំនួនពីរ ដូចខាងក្រោមនេះ៖

១–គោលការប្រាំពីរយ៉ាងនិងការរៀបចំសរសេររបាយការណ៍ ស្តីពីផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិ ឧទេសនាមដោយលោក Alister ។



២–ការធ្វើការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិ ឧទេសនាមដោយលោក Sabesh Shivasabesan ៕



# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ៣០.១១.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា និងសមិទ្ធិផលនានា នៅវត្តព្រៃអង្គរក្នុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម គីម សយសាម៉ាឡៃន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១១.១១.០៩ | ប្រជុំជាមួយទីប្រឹក្សា ADB ស្តីពីអនុកម្មវិធី RIA ការវាយតម្លៃផលប៉ះពាល់នៃបទដ្ឋានគតិយុត្ត សម្រាប់ ECOSOCC ។ |
| ២ | ១២.១១.០៩ | ចូលរួមសន្និសីទស្តីពីសភាពការណ៍សេដ្ឋកិច្ចពិភពលោក ដោយ Thaksin Shinawatra ទីប្រឹក្សាសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។ |
| ៣ | ១៩.១១.០៩ | ប្រជុំជាមួយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** អំពីព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ។ |
| ៤ | ២០.១១.០៩ | ចូលរួមស្តាប់បទបង្ហាញរបស់ទីប្រឹក្សា ADB ស្តីពីការវាតតម្លៃផលប៉ះពាល់នៃបទដ្ឋានគតិយុត្ត។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម ប៉ិច ឈុន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៥.១១.០៩ | ចូលរួមជាកិត្តិយស ដើម្បីថ្លែងសន្ទរកថាក្នុងពិធីបើកវេទិកាគម្រោងកម្មវិធី ស្ពាន-កិច្ចសន្ទនា ដើម្បីវប្បធម៌សន្តិភាព ( Bridges-Dialoques Towards a Culture of Peace ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលសន្និសីទ នៃសាកលវិទ្យាល័យកម្ពុជា។ |
| ២ | ១៨.១១.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសាលពិព័ណ៌សិល្បៈសន្តិភាពពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២១.១១.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលក្នុងកម្មវិធីគម្រោងសាងសង់ផ្ទះរបស់អតីតប្រធានាធិបតីអាមេរិក Jimmmy Cater នៅភូមិព្រះពោធ៌ ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម យឹម ឈាលសន អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៥.១១.០៩ | ចូលរួមជាកិត្តិយស ដើម្បីថ្លែងសន្ទរកថាក្នុងពិធីបើកវេទិកាគម្រោងកម្មវិធី ស្ពាន–កិច្ចសន្ទនា ដើម្បីវប្បធម៌សន្តិភាព ( Bridges-Dialoques Towards a Culture of Peace ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលសន្និសីទ នៃសាកលវិទ្យាល័យកម្ពុជា។ |
| ២ | ១៨.១១.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសាលពិព័ណ៌សិល្បៈសន្តិភាពពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២១.១១.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលក្នុងកម្មវិធីគម្រោងសាងសង់ផ្ទះរបស់អតីតប្រធានាធិបតីអាមេរិក Jimmmy Cater នៅភូមិព្រះពោធ៍ ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម សមាជិក
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |





រូបភាពនៃបទបង្ហាញស្តីពី ការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិនៅកម្ពុជា





ទិដ្ឋភាពនៃកិច្ចប្រជុំពេញអង្គ ១ របស់ក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ក.ស.វ.)

# ព្រឹត្តិបត្រព័ត៌មាន

| | |
|---|---|
| naykRKbRKgTeTA 3 | ឯកឧត្តម គឹម សយសាម៉ាឡែន SmaCk k>s>v> |
| nBnnayk 3 | ឯកឧត្តម វង្ស សំអាន GKe l xaFkar k>s>v> |
| nBnGtbT ngcatEcgTeTA 3 | ឯកឧត្តម អេង រត្នមុនី GKe l xaFkarrg k>s>v> |
| TnakTng nge)aHBmpSay 3 | លោក ម៉ក់ ឆារ៉ា CnykareTsrdm®nTT l bnkkargar k>s>v> |
| beckeTskBüTr 3 | លោក សយ ទាស្លា RbFankarya l y k>s>v> |
| ykBtman ngrbft 3 | លោក ហេង សុភៈបញ្ញា RbFankarya l y k>s>v> |




ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទ ០២៣ ២១១ ៩៤៣ , ០១៦ ៣០៧ ៣៣០

ទូរសារ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in